friends international

Together, building futures. since 1994.






យើងកំពុងស្វែងរកបុគ្គលិកផ្នែក

# សន្តិសុខវេនយប់

តើអ្នកស្រឡាញ់ការងារសន្តិសុខ និងចង់ចូលរួមថែរក្សាសុវត្ថិភាព សណ្តាប់ធ្នាប់ និងការពារទ្រព្យសម្បត្តិ ជាពិសេសជួយបង្កើតបរិយាកាសសុវត្ថិភាពសម្រាប់កុមារ និងស្ថាប័នដែរឬទេ?

ប្រសិនជាអ្នកឆ្លើយថា "ចាស/បាទ" នោះអ្នកអាចជាអ្នកដែលយើងត្រូវការ។

**ការពណ៌នាអំពីអ្វីដែលអ្នកគួរមាន៖**

- មានបទពិសោធន៍ជាសន្តិសុខ
- អត្តចរិកល្អ ម៉ឺងម៉ាត់ ម៉ត់ចត់ ចេះអត់ធ្មត់ រួសរាយរាក់ទាក់ រហ័សរហួន ចូលចិត្តជួយអ្នកដ៏ទៃ និងអាចធ្វើការជាក្រុមបានល្អ
- មានសុខភាពល្អ និងអាចធ្វើការវេនយប់បាន
- អាចសរសេរ អាន អក្សរខ្មែរច្បាស់លាស់
- អាចប្រើប្រាស់ទូរស័ព្ទដៃសម្រាប់ថតរូប និងរាយការណ៍ការងារតាមរយៈតេលេក្រាម

**ទំនួលខុសត្រូវ ៖**

- ធានាសុវត្ថិភាព និងមើលថែ ការពារទ្រព្យសម្បត្តិ សម្ភារៈរបស់ស្ថាប័ន
- ត្រួតពិនិត្យច្រកចេញចូល រៀបចំយានជំនិះអោយមានសណ្តាប់ធ្នាប់ និងដើរល្បាតជាប្រចាំ
- តាមដាន និងរាយការណ៍សកម្មភាពសង្ស័យ ឬហានិភ័យទៅអ្នកគ្រប់គ្រងភ្លាមៗ
- សហការ និងជួយសម្របសម្រួលនៅពេលមានហេតុការណ៍បន្ទាន់ (ភ្លើងឆេះ,ទឹកលិច,ចោរលួច...)
- ជួយការងារបន្ថែមដូចជា ស្រោចទឹក ថែទាំកូនឈើ និងចូលរួមថែរក្សាអនាម័យតាមការបែងចែក
- រាយការណ៍ការងារជាប្រចាំតាមតេលេក្រាម និងបំពេញភារកិច្ចផ្សេងៗតាមការស្នើសុំរបស់អ្នកគ្រប់គ្រង

**លក្ខខណ្ឌការងារ និងអត្ថប្រយោជន៍៖**

- ធ្វើការ៦ថ្ងៃក្នុង១សប្តាហ៍
- ផ្តល់អាហារជូន១ពេល រាល់វេនធ្វើការ
- ថវិកាប្រចាំឆ្នាំ សម្រាប់ចំណាយលើសុខភាពកូន និងមានកន្លែងមើលថែទាំកូន
- បូករួមជាមួយអត្ថប្រយោជន៍ចាំបាច់ទាំងអស់ដូចជា៖ បសស, ប្រាក់សោធន, ប្រាក់អតីតភាពការងារ ព្រមទាំងប្រាក់លើកទឹកចិត្តប្រចាំឆ្នាំ និង ការឈប់សម្រាកដែលមានប្រាក់ខែ។

**ចាប់អារម្មណ៍?**

សូមផ្ញើរប្រវត្តិរូបសង្ខេបរបស់លោកអ្នក**ហើយដាក់ចំនួនប្រាក់ខែដែលអ្នករំពឹងទុក**ទៅកាន់តេលេក្រាម៖

https://t.me/Ah_Khouch17 ពួកយើងរីករាយនឹងស្តាប់ពីអ្នក!

បេក្ខជន ឬបេក្ខនារីទាំងអស់នឹងឆ្លងកាត់ការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើគោលការណ៍ការការពារកុមារ និងកិច្ចការពារប្រឆាំងនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (Beneficiary Protection Policy and PSEA Policy) ។

Powered by friends international

Together, building futures.